ក

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 30 ខែ 05 ឆ្នាំ 2013

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១- ព្រះរាជក្រម


| | | |
|---|---|---|
| ០៣-១១-២០០០ | -ព្រះរាជក្រម នស/រកម/១១០០/១០ ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈ ឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ | ១៧៣៦ |


### ២- ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ០៣-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨១ បំពាក់មេដាយឯករាជជាតិ ជូនដល់ កងយោធពលខេមរភូមិន្ទ នៃព្រះរាជាណាចក្រកម្ពុជា | ១៧៤១ |
| ០៤-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨២ បំពាក់មេដាយសហមេត្រីថ្នាក់ធិបឌិន្ទ ជូនដល់កងទ័ពភូមិន្ទថៃ | ១៧៤២ |
| ០៥-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៣ បំពាក់មេដាយសហមេត្រីថ្នាក់ធិបឌិន្ទ ជូនដល់កងទ័ពប្រជាជនវៀតណាម | ១៧៤៣ |
| ០៦-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៤ បំពាក់មេដាយសហមេត្រីថ្នាក់ធិបឌិន្ទ ជូនដល់កងទ័ពប្រជាជនលាវ | ១៧៤៤ |
| ០៧-១១-២០០០ | ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៥ បន្ថយរយៈពេលរងទោសជូនដល់ទណ្ឌិតដែលបានកែប្រែខ្លួនបានល្អ | ១៧៤៥ |
| ០៧-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៦ តែងតាំងលោក សូ ខុន ជាឧកញ៉ា | ១៧៤៥ |
| ០៨-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៧ តែងតាំងលោក សូ សុទណ្ណ ជាឧកញ៉ា | ១៧៤៦ |
| ០៩-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៨ តែងតាំងឯកឧត្តម គង់ គេង ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី | ១៧៤៦ |
| ០៧-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៩ បំពាក់មេដាយសេនាជ័យសិទ្ធ ជូននាយទាហានជើងចាស់ចំនួន ១២ រូប | ១៧៤៧ |

| | | |
|---|---|---|
| ០៧-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨០ បំពាក់មេដាយព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេនា ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ | ១៧៥៨ |
| ០៧-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨១ តែងតាំងឯកឧត្តម ញឹម វណ្ណដា ជាអនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ១៧៥៩ |
| ០៨-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨២ អនុញ្ញាតិអោយឯកឧត្តម នូ សុវណ្ណារ៉ា លាឈប់ពីមុខតំណែង | ១៧៦០ |
| ០៨-១១-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៣ តែងតាំងលោកជំទាវ ឡេង សុខឃាន ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា | ១៧៦១ |


## II- រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ០២-១១-២០០០ | -អនុក្រឹត្យលេខ ៧៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ១៧៦២ |
| ០៦-១១-២០០០ | -អនុក្រឹត្យលេខ ៧៧ អនក្រ.បក ស្តីពីការកែសំរួលអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការកែសំរួលការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ១៧៦៣ |
| ០៨-១១-២០០០ | -អនុក្រឹត្យលេខ ៧៨ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ១៧៦៥ |
| ០៨-១១-២០០០ | -អនុក្រឹត្យលេខ ៧៩ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ១៧៦៦ |
| ០៣-១១-២០០០ | -អនុក្រឹត្យលេខ ៣៧១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៧៦៨ |
| ០៣-១១-២០០០ | -អនុក្រឹត្យលេខ ៣៧២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ១៧៦៩ |
| ០៣-១១-២០០០ | -អនុក្រឹត្យលេខ ៣៧៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៧៧០ |
| ០៣-១១-២០០០ | -អនុក្រឹត្យលេខ ៣៧៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៧៧០ |
| ០៣-១១-២០០០ | -អនុក្រឹត្យលេខ ៣៧៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៧៧២ |
| ០៦-១១-២០០០ | -អនុក្រឹត្យលេខ ៣៧៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៧៧៣ |
| ០៦-១១-២០០០ | -អនុក្រឹត្យលេខ ៣៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៧៧៥ |
| ០៨-១១-២០០០ | -អនុក្រឹត្យលេខ ៣៧៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៧៧៨ |

## III- ការងារបណ្ដាក្រសួង

## ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### ប្រកាស


០៣-១១-២០០០ -ប្រកាសលេខ ១០៧៥ យអក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ ចេង សុីន អន្លង់ត្រា ជាឧបសម្ព័ន្ធអនុវិទ្យាល័យព្រៃកអន្ទះ ស្ថិតនៅក្នុងភូមិអន្លង់ត្រា ឃុំព្រែកជ្រៃ ស្រុកកំពង់លាវ ខេត្តព្រៃវែង ១៧៧៦

០៨-១១-២០០០ -ប្រកាសលេខ ១០៨០ យអក.ប្រក ស្ដីពីការពង្រីក និងប្ដូរឈ្មោះអនុវិទ្យាល័យ សំរោង ទៅជាវិទ្យាល័យ ឧត្ដរមានជ័យ ស្ថិតនៅក្នុងឃុំសំរោង ស្រុកសំរោង ខេត្តឧត្ដរមានជ័យ ១៧៧៧

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/១១០០/១០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែល ប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១-១២-១៣-១៨-២២-២៤-២៦-២៨-៣០-៣៤-៥១-៩០-៩១-៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី១៤ នៃ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់ទាំងស្រុង កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ លើកទី១ លើកលែងតែចំណុចទី៤នៃមាត្រាទី៣ ក្នុងជំពូកទី១ ប៉ុន្តែត្រូវបានរដ្ឋសភាធ្វើការបោះឆ្នោតអនុម័តជាថ្មី ដោយមិនយល់ព្រមតាមសំណើរបស់

ព្រឹទ្ធសភានាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី២ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០០ ហើយបានដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

## ស្តីពី

# ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន

# ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ

# និង ជំនួយវេជ្ជសាស្ត្រ

***

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ច្បាប់នេះមានគោលដៅកំណត់បែបបទនិងលក្ខខ័ណ្ឌនៃការប្រព្រឹត្តទៅសំរាប់ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ .-**

ត្រូវបានចាត់ទុកជា :

- អ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ គឺគ្រូពេទ្យ ឱសថការី ទន្តពេទ្យ និងឆ្មប ។
- អ្នកប្រកបវិជ្ជាជីវៈជំនួយវេជ្ជសាស្ត្រគឺ គិលានុបដ្ឋាក គិលានុបដ្ឋាយិកា អ្នកបច្ចេកទេសមន្ទីរពិសោធន៍ អ្នកព្យាបាលដោយចលនា អ្នកបច្ចេកទេសធ្មេញនិងអ្នកប្រកបវិជ្ជាជីវៈប្រហាក់ប្រហែលផ្សេងទៀត ។

មុខវិជ្ជាជីវៈប្រហាក់ប្រហែលដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៣ ._

មានសិទ្ធិប្រកបវិជ្ជាជីវៈជាអ្នកវេជ្ជសាស្ត្រ អ្នកអមវេជ្ជសាស្ត្រនិងអ្នកជំនួយវេជ្ជសាស្ត្របាន ចំពោះជនណាដែលមានលក្ខណសម្បត្តិដូចខាងក្រោមនេះ :

- មានសញ្ជាតិខ្មែរ
- មានសញ្ញាប័ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល
- បានចុះឈ្មោះក្នុងបញ្ជីសមាជិកគណៈគ្រូពេទ្យ គណៈឱសថការី គណៈទន្តពេទ្យ គណៈឆ្មប គណៈគិលានុប្បដ្ឋាក
- មិនដែលមានទោសពីបទល្មើសព្រហ្មទណ្ឌណាមួយ
- មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន ។

មាត្រា ៤ ._

អាចអនុញ្ញាតឲ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ ជាអ្នកអមវេជ្ជសាស្ត្រនិងជាអ្នកជំនួយវេជ្ជសាស្ត្រ ដែលមានកិត្តិនាមល្បីល្បាញឯកទេសខ្ពស់ប្រកបវិជ្ជាជីវៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ។ បែបបទនិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី២

## ការបើក ការកែប្រែទំហំនិងការបិទសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

មាត្រា ៥ ._

ការបើក ការកែប្រែទំហំបន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ពិគ្រោះព្យាបាលជំងឺមន្តវេទនសាស្ត្រ (មាត់ធ្មេញ) បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់សោភ័ណសល្យសាស្ត្រ មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរសម្ភពមន្ទីរសំរាកព្យាបាលពហុព្យាបាល សេវាវេជ្ជសាស្ត្រអមវេជ្ជសាស្ត្រឬជំនួយវេជ្ជសាស្ត្រឯកជនផ្សេងទៀត ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។ ក្រោយពីបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ហើយត្រូវអនុវត្តតាមនីតិវិធីជាធរមាន ។

ចំពោះការបិទវិញត្រូវសុំច្បាប់ពីក្រសួងសុខាភិបាល ។

មាត្រា ៦ ._

អ្នកមានសិទ្ធិប្រកបវិជ្ជាជីវៈដូចមានចែងក្នុងមាត្រា ៣នៃច្បាប់នេះ អាចមានសិទ្ធិសុំបើក :

- បន្ទប់ពិគ្រោះព្យាបាលជំងឺឯកជនបាន ចំពោះតែវេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម
- បន្ទប់ពិគ្រោះព្យាបាលជំងឺទន្តវេទនសាស្ត្រ (មាត់ធ្មេញ) ឯកជនបាន ចំពោះតែទន្តបណ្ឌិត ទន្តពេទ្យ ឬគ្រូពេទ្យឯកទេសមាត់

- បន្ទប់ព្យាបាលដោយចលនាឯកជនបាន ចំពោះតែអ្នកព្យាបាលដោយចលនា
- បន្ទប់ថែទាំជំងឺឯកជនបានចំពោះតែគិលានុបដ្ឋាកមធ្យម ឬគិលានុបដ្ឋាយិកាមធ្យម
- បន្ទប់សោភ័ណសល្យសាស្ត្រឯកជនបាន ចំពោះតែវេជ្ជបណ្ឌិតដែលមានឯកទេសជំនាញផ្នែកនេះ
- មន្ទីរពិសោធន៍វេជ្ជសាស្ត្រឯកជនបាន ចំពោះតែវេជ្ជបណ្ឌិតឱសថបណ្ឌិត ឬឱសថការីឧត្តមដែលមានឯកទេសជំនាញមន្ទីរពិសោធន៍
- មន្ទីរសម្ភព មន្ទីរសំរាកព្យាបាលពហុព្យាបាលឯកជនបាន ចំពោះតែវេជ្ជបណ្ឌិត ។

ដោយឡែកចំពោះឆ្មបមធ្យមមានសិទ្ធិបើកតែបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះឯកជនប៉ុណ្ណោះ ។

មាត្រា ៧ ._

មន្ទីរសម្ភព មន្ទីរសំរាកព្យាបាលពហុព្យាបាលឯកជនទាំងឡាយដែលមានគ្រែសំរាប់អ្នកជំងឺសំរាកព្យាបាល និងមន្ទីរ ពិសោធន៍វេជ្ជសាស្ត្រឯកជនត្រូវមានវត្តមានរបស់អ្នកទទួលខុសត្រូវ ។

ក្នុងករណីអវត្តមានអ្នកទទួលខុសត្រូវ ត្រូវមានអ្នកជំនួស ។ លក្ខណសម្បត្តិនៃអ្នកទទួលខុសត្រូវ និងអ្នកត្រូវជំនួស ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មាត្រា ៨ ._

អ្នកវេជ្ជសាស្ត្រ អ្នកអមវេជ្ជសាស្ត្រឬអ្នកជំនួយវេជ្ជសាស្ត្រមួយរូប មានសិទ្ធិសុំបើកសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ឬជំនួយវេជ្ជសាស្ត្រឯកជនរបស់ខ្លួនបានតែមួយកន្លែង ទោះជាអ្នកនោះមានសញ្ញាប័ត្រឯកទេសច្រើនក៏ដោយ ។

មាត្រា ៩ ._

បែបបទពិងលក្ខខ័ណ្ឌនៃការសុំបើក សុំពង្រីកទ្រង់ទ្រាយ សុំបិទ ព្រមទាំងលក្ខខ័ណ្ឌបច្ចេកទេសនៃសេវាវេជ្ជសាស្ត្រ សេវាអមវេជ្ជសាស្ត្រនិងសេវាជំនួយវេជ្ជសាស្ត្រ ឯកជនត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី៣

## សមត្ថកិច្ចក្នុងការគ្រប់គ្រងនិងការត្រួតពិនិត្យ

មាត្រា ១០ ._

ការណែនាំ ការគ្រប់គ្រង ការត្រួតពិនិត្យរាល់សកម្មភាពនៃវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ជំនួយដោយគណៈវិជ្ជាជីវៈសមស្របតាមក្រមសីលធម៌ តាមមុខវិជ្ជាជីវៈនីមួយៗ ។

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈវិជ្ជជីវៈនីមួយៗ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

បទប្បញ្ញត្តិស្តីពីក្រមសីលធម៌តាមមុខវិជ្ជាជីវៈនីមួយៗត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១១ ._

ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មត្រូវហាមឃាត់ជាដាច់ខាត លើកលែងតែការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌវិជ្ជាជីវៈ ដែលមិនប៉ះពាល់ដល់ក្រមសីលធម៌ហើយត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មាត្រា ១២ ._

ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ត្រូវឋិតនៅក្រោមរបបនីតិវិធីរួមអំពីពន្ធ និងអាករ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់ ។

## ជំពូកទី៤

## ទោសប្បញ្ញត្តិ

មាត្រា ១៣ ._

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ដល់ ៥.០០០.០០០ (ប្រាំលាន)រៀល និងផ្អាកដំណើរការសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ពី១ខែទៅ ៣ខែ ឬទោសណាមួយក្នុងចំណោមទោសទាំងពីរនេះដោយពុំទាន់គិតពីបទល្មើសផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ មាត្រា ៦ មាត្រា ៧ មាត្រា ៨ មាត្រា១១ ឬ មាត្រា១២ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេមួយជាពីរនិងផ្អាកដំណើរការសេវា ឬបញ្ឈប់ជាស្ថាពរ ។

មាត្រា ១៤ ._

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ចំពោះជនណាដែលរារាំងមិនឲ្យភ្នាក់ងារមានសមត្ថកិច្ចបំពេញភារកិច្ចអធិការកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ១០ ខាងលើ ។

មាត្រា ១៥ ._

ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ១៣ ឬ ១៤ ចំពោះមន្ត្រីរាជការ ឬជនណាដែលបានឃុបឃិត ឬប្រព្រឹត្តរំលោភលើភារកិច្ចរបស់ខ្លួន ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

មាត្រា ១៦ ._

ក្នុងរយៈពេល ៦ (ប្រាំមួយ) ខែយ៉ាងយូរ បន្ទាប់ពីច្បាប់នេះចូលជាធរមានអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ដែលក្រសួងសុខាភិបាលបានចេញលិខិតអនុញ្ញាត

ឲ្យបើកសេវាជាផ្លូវការហើយនោះ ត្រូវបំពេញបន្ថែមនូវទំរង់បែបបទឲ្យត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**ជំពូកទី៦**

**អវសានប្បញ្ញត្តិ**

**មាត្រា ១៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល

ហត្ថលេខា

**ហុង ស៊ុនហួត**

★★★

# ២- ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យ នស/រកត/១១០០/១៩១**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៩ស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- យោងតាមសំណើរបស់សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០០

**ត្រាស់បង្គាប់**

មាត្រា ១.- ត្រូវបានបំពាក់មេដាយ **ឯករាជជាតិ** ជូនដល់កងយោធពលខេមរភូមិន្ទ នៃព្រះរាជាណាចក្រកម្ពុជា

មាត្រា ២.- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

**ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨២**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- យោងតាមសំណើរបស់សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០០

ត្រាស់បង្គាប់

មាត្រា ១._ ត្រូវបានបំពាក់មេដាយ សហមេត្រី ថ្នាក់ ធិបឌិន្ទ ជូនដល់កងទ័ពភូមិន្ទថៃ ។

មាត្រា ២._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០
ព្រះហស្តលេខា
នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការ បង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការពារជាតិ
- យោងតាមសំណើរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០០

**ត្រាស់បង្គាប់**

មាត្រា ១._ ត្រូវបានបំពាក់មេដាយ សហមេត្រី ថ្នាក់ និបឌិន្ទ ជូនដល់គងទ័ពប្រជាជនវៀតណាម ។

មាត្រា ២._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

***

**ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៤**

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការ បង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- យោងតាមសំណើរបស់សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០០០

ត្រាស់បង្គាប់

មាត្រា ១._ ត្រូវបានបំពាក់មេដាយ **សហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនដល់កងទ័ពប្រជាជនលាវ ។

មាត្រា ២._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

ភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

**ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៥**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

**បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**

**បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០-៦-៨៨**

**ត្រាស់បង្គាប់**

មាត្រា ១._ ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម :

១- ទណ្ឌិតឈ្មោះ **ចាន់ សុខុម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៤ ចុះថ្ងៃទី២៤-១០-១៩៨៦ របស់តុលាខេត្តព្រៃវែង ។

២- ទណ្ឌិតឈ្មោះ **ឡឹក ឃន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ មួយជីវិត តាមអំណាចសាលក្រមលេខ ៥ ចុះថ្ងៃទី៣០-១០-១៩៨៥ របស់តុលាខេត្តតាកែវ ។

៣- ទណ្ឌិតឈ្មោះ **គឹម សារិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ ៥ ចុះថ្ងៃទី៣០-១០-១៩៨៧ របស់តុលាខេត្តតាកែវ ។

៤- ទណ្ឌិតឈ្មោះ **ហង់ ទ៊ាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់មួយជីវិត តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី១០-៦-១៩៩៥ របស់តុលាខេត្តកោះកុង ។

៥- ទណ្ឌិតឈ្មោះ **គ្រូឌ សារឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី០១-៧-១៩៩៣ របស់តុលាខេត្តសៀមរាប ។

៦- ទណ្ឌិតឈ្មោះ **សាន រី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥០ ចុះថ្ងៃទី១៧-៦-១៩៩៥ របស់តុលាខេត្តកណ្តាល ។

មាត្រា ២.- ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ខែ ឲ្យទណ្ឌិតចំនួន ២៣នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១- ទណ្ឌិតឈ្មោះ **ខៀន ឆឹទ៊ុកហាន់** ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ១០-៦-៩៣ របស់តុលាការខេត្តព្រៃវែង ។

២ ទណ្ឌិតឈ្មោះ **ហោ ហ៊ន់** ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ ចុះថ្ងៃទី ២៥-៨-៩៣ របស់តុលាការខេត្តព្រៃវែង ។

៣- ទណ្ឌិតឈ្មោះ **ឯម ហោ** ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ១២-៤-៩៥ របស់តុលាការខេត្តតាកែវ ។

៤- ទណ្ឌិតឈ្មោះ **ឡេង ជា** ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ ចុះថ្ងៃទី ០៥-៤-៩៥ របស់តុលាការខេត្តតាកែវ ។

៥- ទណ្ឌិតឈ្មោះ **ខ៊ែត គោញ** ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ ចុះថ្ងៃទី ១៤-៦-៩៥ របស់តុលាការខេត្តតាកែវ ។

៦- ទណ្ឌិតឈ្មោះ **ប្រាក់ ស៊ីន** ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ១២-៣-៩៦ របស់តុលាការខេត្តតាកែវ ។

៧- ទណ្ឌិតឈ្មោះ **ឈេម រ៉ូ** ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ ចុះថ្ងៃទី ០៨-៤-៩៦ របស់តុលាការខេត្តក្រចេះ ។

៨- ទណ្ឌិតឈ្មោះ **សេង សុគ័ណ** ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៦២ ចុះថ្ងៃទី ០៨-១០-៩៧ របស់តុលាការខេត្តក្រចេះ ។

៩- ទណ្ឌិតឈ្មោះ ឡេង ឡាយ ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៣០ ចុះថ្ងៃទី ២៨-៣-៩៥ របស់តុលាការខេត្តសៀមរាប ។

១០- ទណ្ឌិតឈ្មោះ អ៊ូ ស៊ីថា ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០៤-៥-៩៥ របស់តុលាការខេត្តសៀមរាប ។

១១- ទណ្ឌិតឈ្មោះ មូល តេខ ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី ២៤-៨-៩៥ របស់តុលាការខេត្តសៀមរាប ។

១២- ទណ្ឌិតឈ្មោះ ថេន នី ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ ចុះថ្ងៃទី ១៧-០១-៩៦ របស់តុលាការខេត្តសៀមរាប ។

១៣- ទណ្ឌិតឈ្មោះ ឡូត យន់ ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៩២ ចុះថ្ងៃទី ១៦-៨-៩៦ របស់តុលាការខេត្តសៀមរាប ។

១៤- ទណ្ឌិតឈ្មោះ ថុល សុនី ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១០២ ចុះថ្ងៃទី ២៦-៩-៩៦ របស់តុលាការខេត្តសៀមរាប ។

១៥- ទណ្ឌិតឈ្មោះ តែវន ថាត់ ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ០៣-០១-៩៧ របស់តុលាការខេត្តសៀមរាប ។

១៦- ទណ្ឌិតឈ្មោះ ឌន ដុំ ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៣ ចុះថ្ងៃទី ៣០-០៥-៩៦ របស់តុលាការខេត្តសៀមរាប ។

១៧- ទណ្ឌិតឈ្មោះ ព្រុំ ទ័ក ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៣ ចុះថ្ងៃទី ៣០-០៥-៩៦ របស់តុលាការខេត្តសៀមរាប ។

១៨- ទណ្ឌិតឈ្មោះ ម៉ុត សំបាន ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៥ ចុះថ្ងៃទី ១៥-១០-៩៧ របស់តុលាការខេត្តសៀមរាប ។

១៩- ទណ្ឌិតឈ្មោះ តឹក ម៉ឹក ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៣ ចុះថ្ងៃទី០៤-០៥-៩៥ របស់តុលាការខេត្តសៀមរាប ។

២០- ទណ្ឌិតឈ្មោះ សូ ឡឿ ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៦ ចុះថ្ងៃទី០៤-០៥-៩៥ របស់តុលាការខេត្តសៀមរាប ។

២១- ទណ្ឌិតឈ្មោះ លី លួម ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី២៤-០៨-៩៥ របស់តុលាការខេត្តសៀមរាប ។

២២- ទណ្ឌិតឈ្មោះ សៀង ឌូ ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១២៥ ចុះថ្ងៃទី២៣-០៥-៩៥ របស់តុលាការខេត្តកណ្តាល ។

២៣- ទណ្ឌិតឈ្មោះ ថន សេង ដែលត្រូវបានសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលដីកាលេខ ២៤ ចុះថ្ងៃទី១៥-០៨-៩៧ របស់តុលាការកំពូល ។

មាត្រា ៣._ ត្រូវបន្ថយរយៈពេលរងទោសចំនួន ៦ខែ ឲ្យទណ្ឌិតចំនួន ៩៦នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១- ទណ្ឌិតឈ្មោះ ស្រី ឌួន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី២៣-០៥-៩៧ របស់តុលាការខេត្តព្រះវិហារ ។

២- ទណ្ឌិតឈ្មោះ ចែត អោត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី២១-១០-៩៥ របស់តុលាការខេត្តព្រះវិហារ ។

៣- ទណ្ឌិតឈ្មោះ មូល ជា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី០៣-០៤-៩៦ របស់តុលាការខេត្តព្រះវិហារ ។

៤- ទណ្ឌិតឈ្មោះ ចេង សុផុន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី២២-១១-៩៥ របស់តុលាការខេត្តព្រះវិហារ ។

៥- ទណ្ឌិតឈ្មោះ ខិន គិមសួន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩ ចុះថ្ងៃទី ០៩-០៦-៩៣ របស់តុលាការខេត្តព្រៃវែង ។

៦- ទណ្ឌិតឈ្មោះ ដាន់ កុសល់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលដីកាលេខ ៣០ ចុះថ្ងៃទី ០៣-១០-៩៧ របស់តុលាការកំពូល ។

៧- ទណ្ឌិតឈ្មោះ ហួន យ៉ន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៩ ចុះថ្ងៃទី ១០-៩-៩៦ របស់តុលាការខេត្តតាកែវ ។

៨- ទណ្ឌិតឈ្មោះ ងាញ់ រិច ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២៨ ចុះថ្ងៃទី ១៥-៦-៩៥ របស់តុលាការខេត្តតាកែវ ។

៩- ទណ្ឌិតឈ្មោះ ម៉ឹក ថា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៦០ ចុះថ្ងៃទី ១៤-១១-៩៥ របស់តុលាការខេត្តតាកែវ ។

១០- ទណ្ឌិតឈ្មោះ គង សុន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ ចុះថ្ងៃទី ១៤-០៥-៩៥ របស់តុលាការខេត្តតាកែវ ។

១១- ទណ្ឌិតឈ្មោះ ស៊ិន ផល ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ ចុះថ្ងៃទី ១២-០៣-៩៩ របស់តុលាការខេត្តក្រចេះ ។

១២- ទណ្ឌិតឈ្មោះ អ៊ុល គឹមហួ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៥១ ចុះថ្ងៃទី ០១-០៤-៩៩ របស់តុលាការខេត្តក្រចេះ ។

១៣- ទណ្ឌិតឈ្មោះ ជុំ ពៅ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ១៩-០៦-៩៨ របស់តុលាការខេត្តកោះកុង ។

១៤- ទណ្ឌិតឈ្មោះ សៀម យន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី ២៩-០៦-៩៥ របស់តុលាការខេត្តកោះកុង ។

១៥- ទណ្ឌិតឈ្មោះ ចាន់ ជឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ២៩-០៦-៩៥ របស់តុលាការខេត្តកោះកុង ។

១៦- ទណ្ឌិតឈ្មោះ ម៉េន ទ្រី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២ ចុះថ្ងៃទី ១៦-០៩-៩៥ របស់តុលាការខេត្តកោះកុង ។

១៧- ទណ្ឌិតឈ្មោះ បួន សុភលី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៨២ "ក" ចុះថ្ងៃទី ០២-០៩-៩៨ របស់តុលាការខេត្តកំពង់ចាម ។

១៨- ទណ្ឌិតឈ្មោះ ដួង ពេជ្រ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ "ខ" ចុះថ្ងៃទី ២២-១០-៩៨ របស់តុលាការខេត្តកំពង់ចាម ។

១៩- ទណ្ឌិតឈ្មោះ ម៉ី រុំ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៧២ "ក" ចុះថ្ងៃទី ០៥-០៨-៩៨ របស់តុលាការខេត្តកំពង់ចាម ។

២០- ទណ្ឌិតឈ្មោះ ឯក សែវ៉ាន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ១១២ "ក" ចុះថ្ងៃទី ២៧-១០-៩៩ របស់តុលាការខេត្តកំពង់ចាម ។

២១- ទណ្ឌិតឈ្មោះ ខឹន ធីន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៥០ "ក" ចុះថ្ងៃទី ២៧-០៥-៩៩ របស់តុលាការខេត្តកំពង់ចាម ។

២២- ទណ្ឌិតឈ្មោះ ឈន រ័ត្ន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៥០ "ក" ចុះថ្ងៃទី ២៧-០៥-៩៩ របស់តុលាការខេត្តកំពង់ចាម ។

២៣- ទណ្ឌិតឈ្មោះ តឿន ថា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២ "ក" ចុះថ្ងៃទី ០៦-០៥-៩៩ របស់តុលាការខេត្តកំពង់ចាម ។

២៤- ទណ្ឌិតឈ្មោះ ឆែម ឈឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៩០ "ក" ចុះថ្ងៃទី ២៩-០៩-៩៨ របស់តុលាការខេត្តកំពង់ចាម ។

២៥- ទណ្ឌិតឈ្មោះ ឆា ឆាន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ "ក" ចុះថ្ងៃទី ១៦-០៣-៩៩ របស់តុលាការខេត្តកំពង់ចាម ។

២៦- ទណ្ឌិតឈ្មោះ ហេង ជា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាច សាលក្រមលេខ ៣២ "ក" ចុះថ្ងៃទី ០៦-០៥-៩៩ របស់តុលាការខេត្តកំពង់ចាម ។

២៧- ទណ្ឌិតឈ្មោះ យ៉ាន យាត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាច សាលក្រមលេខ ១៥០ "ក" ចុះថ្ងៃទី ២២-១២-៩៩ របស់តុលាការខេត្តកំពង់ចាម ។

២៨- ទណ្ឌិតឈ្មោះ ហួន ផេត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាច សាលក្រមលេខ ១២ "ក" ចុះថ្ងៃទី ១១-០៣-៩៩ របស់តុលាការខេត្តកំពង់ចាម ។

២៩- ទណ្ឌិតឈ្មោះ ហ៊ាន ម៉ុន្នីញ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាច សាលក្រមលេខ ៤ "គ" ចុះថ្ងៃទី ១៩-០១-២០០០ របស់តុលាការខេត្តកំពង់ចាម ។

៣០- ទណ្ឌិតឈ្មោះ ផុន ឃឹម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាច សាលក្រមលេខ ១៣៨ "ក" ចុះថ្ងៃទី ១៦-១២-៩៩ របស់តុលាការខេត្តកំពង់ចាម ។

៣១- ទណ្ឌិតឈ្មោះ ម៉ុត ធឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាច សាលក្រមលេខ ៣៨ ចុះថ្ងៃទី ០៦-០៦-៩៧ របស់តុលាការខេត្តសៀមរាប ។

៣២- ទណ្ឌិតឈ្មោះ សាយ សុច ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាច សាលក្រមលេខ ២៥ ចុះថ្ងៃទី ២២-០៤-៩៧ របស់តុលាការខេត្តសៀមរាប ។

៣៣- ទណ្ឌិតឈ្មោះ ថា សុខ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាច សាលក្រមលេខ ១០ ចុះថ្ងៃទី ២៣-០២-៩៨ របស់តុលាការខេត្តសៀមរាប ។

៣៤- ទណ្ឌិតឈ្មោះ ឃុត ផេង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាច សាលក្រមលេខ ២៥ ចុះថ្ងៃទី ២២-០៤-៩៧ របស់តុលាការខេត្តសៀមរាប ។

៣៥- ទណ្ឌិតឈ្មោះ ធួន យ៉ាន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាច សាលក្រមលេខ ១១ ចុះថ្ងៃទី ២៩-០១-៩៩ របស់តុលាការខេត្តសៀមរាប ។

៣៦- ទណ្ឌិតឈ្មោះ ពាច ហាម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាច សាលក្រមលេខ ១៧ ចុះថ្ងៃទី ២៥-០២-៩៧ របស់តុលាការខេត្តសៀមរាប ។

៣៧- ទណ្ឌិតឈ្មោះ កុខ ធន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាច សាលក្រមលេខ ៥៣ ចុះថ្ងៃទី ០៦-០៧-៩៩ របស់តុលាការខេត្តសៀមរាប ។

៣៨- ទណ្ឌិតឈ្មោះ គ្រួច សារ៉ាត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាច សាលក្រមលេខ ២៦ ចុះថ្ងៃទី ២៩-០៤-៩៨ របស់តុលាការខេត្តសៀមរាប ។

៣៩- ទណ្ឌិតឈ្មោះ សុខ យ៉ាន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាច សាលក្រមលេខ ១១ ចុះថ្ងៃទី ១៩-០១-៩៦ របស់តុលាការខេត្តសៀមរាប ។

៤០- ទណ្ឌិតឈ្មោះ លឹម ហេង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាច សាលក្រមលេខ ១១ ចុះថ្ងៃទី ១៩-០១-៩៦ របស់តុលាការខេត្តសៀមរាប ។

៤១- ទណ្ឌិតឈ្មោះ ពៅ សក្តិ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាច សាលក្រមលេខ ១១ ចុះថ្ងៃទី ១៩-០១-៩៦ របស់តុលាការខេត្តសៀមរាប ។

៤២- ទណ្ឌិតឈ្មោះ ព្រិន ភ្លាម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាច សាលក្រមលេខ ១០៤ ចុះថ្ងៃទី ១៤-១២-៩៩ របស់តុលាការខេត្តសៀមរាប ។

៤៣- ទណ្ឌិតឈ្មោះ គាំ ឡុយ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាច សាលក្រមលេខ ៣៨ ចុះថ្ងៃទី ០៦-០៦-៩៧ របស់តុលាការខេត្តសៀមរាប ។

៤៤- ទណ្ឌិតឈ្មោះ ផន នឹន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាច សាលក្រមលេខ ៣៣ ចុះថ្ងៃទី ១៧-០៣-២០០០ របស់តុលាការខេត្តសៀមរាប ។

៤៥- ទណ្ឌិតឈ្មោះ ស៊ាន សៃ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាច សាលក្រមលេខ ៥៥ ចុះថ្ងៃទី ៩-០៦-៩៥ របស់តុលាការខេត្តសៀមរាប ។

៤៦- ទណ្ឌិតឈ្មោះ ឡាំ ផាន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាច សាលក្រមលេខ ៨៧ ចុះថ្ងៃទី ១៤-០៩-៩៥ របស់តុលាការខេត្តសៀមរាប ។

៤៧ ទណ្ឌិតឈ្មោះ ស៊ុខ សឿម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាច សាលក្រមលេខ ៣១ ចុះថ្ងៃទី ២៣-០២-៩៦ របស់តុលាការខេត្តសៀមរាប ។

៤៨- ទណ្ឌិតឈ្មោះ យួន គក់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាច សាលក្រមលេខ ៣១ ចុះថ្ងៃទី ២៣-០២-៩៦ របស់តុលាការខេត្តសៀមរាប ។

៤៩- ទណ្ឌិតឈ្មោះ ទេព ឡិន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ឆ្នាំ តាមអំណាច សាលក្រមលេខ ៣៤ ចុះថ្ងៃទី ២៨-០២-៩៦ របស់តុលាការខេត្តសៀមរាប ។

៥០- ទណ្ឌិតឈ្មោះ ញូ ញ៉ូយ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៩ឆ្នាំ តាមអំណាច សាលក្រមលេខ ៣៤ ចុះថ្ងៃទី ២៨-០២-៩៦ របស់តុលាការខេត្តសៀមរាប ។

៥១- ទណ្ឌិតឈ្មោះ ញៀន ឆយ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាច សាលក្រមលេខ ៨០ ចុះថ្ងៃទី ១៥-០៩-៩៨ របស់តុលាការខេត្តសៀមរាប ។

៥២- ទណ្ឌិតឈ្មោះ សេង ឈាំ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាច សាលក្រមលេខ ៥៣ ចុះថ្ងៃទី ៣០-០៤-៩៦ របស់តុលាការខេត្តសៀមរាប ។

៥៣- ទណ្ឌិតឈ្មោះ ម៉ិក ឈេង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាច សាលក្រមលេខ ៩២ ចុះថ្ងៃទី ១៦-០៨-៩៦ របស់តុលាការខេត្តសៀមរាប ។

៥៤- ទណ្ឌិតឈ្មោះ ឃឹម សំណាង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ០៣-០១-៩៦ របស់តុលាការខេត្តសៀមរាប ។

៥៥- ទណ្ឌិតឈ្មោះ គុម ម៉ោល ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ២៣-០២-៩៨ របស់តុលាការខេត្តសៀមរាប ។

៥៦- ទណ្ឌិតឈ្មោះ ឡេង ឡិនហ៊ីង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ "ង" ចុះថ្ងៃទី ១៩-០៥-៩៥ របស់តុលាការក្រុងភ្នំពេញ ។

៥៧- ទណ្ឌិតឈ្មោះ ជា ម៉ុង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលដីកាលេខ ១៥ ចុះថ្ងៃទី ២៩-១២-៩៥ របស់តុលាការកំពូល ។

៥៨- ទណ្ឌិតឈ្មោះ នួន សុខេន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលដីកាលេខ ១២៦ ចុះថ្ងៃទី ១០-០៦-៩៨ របស់សាលាឧទ្ធរណ៍ ។

៥៩- ទណ្ឌិតឈ្មោះ សេង សារិន្ទ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលដីកាលេខ ១២៦ ចុះថ្ងៃទី ១០-៦-៩៨ របស់សាលាឧទ្ធរណ៍ ។

៦០- ទណ្ឌិតឈ្មោះ ថោ ចំណាន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលដីកាលេខ ១៦១ ចុះថ្ងៃទី ១៧-៧-៩៨ របស់សាលាឧទ្ធរណ៍ ។

៦១- ទណ្ឌិតឈ្មោះ ឈុន នី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលដីកាលេខ ១៦១ ចុះថ្ងៃទី ១៧-៧-៩៨ របស់សាលាឧទ្ធរណ៍ ។

៦២- ទណ្ឌិតឈ្មោះ គឹម សំអាត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលដីកាលេខ ១៦១ ចុះថ្ងៃទី ១៧-៧-៩៨ របស់សាលាឧទ្ធរណ៍ ។

៦៣- ទណ្ឌិតឈ្មោះ ដេន សុត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨"ឈ" ចុះថ្ងៃទី ២៥-៥-៩៩ របស់តុលាការក្រុងភ្នំពេញ ។

៦៤- ទណ្ឌិតឈ្មោះ យ៉ាន់ សារ៉េន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៨ ចុះថ្ងៃទី ១២-៥-៩៥ របស់តុលាការខេត្តកណ្តាល ។

៦៥- ទណ្ឌិតឈ្មោះ ខ៊ូ ខន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩៦ ចុះថ្ងៃទី ១៦-៨-៩៥ របស់តុលាការខេត្តកណ្តាល ។

៦៦- ទណ្ឌិតឈ្មោះ ចាន់ ស៊ីផាត ហៅ ឆក ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ ៦ខែ តាមអំណាច សាលក្រមលេខ ១៧"ភ" ចុះថ្ងៃទី ១៣-៥-៩៩ របស់តុលាការខេត្តកណ្តាល ។

៦៧- ទណ្ឌិតឈ្មោះ ឌេត តន្ត្រី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣"ភ" ចុះថ្ងៃទី ១២-៧-៩៩ របស់តុលាការខេត្តកណ្តាល ។

៦៨- ទណ្ឌិតឈ្មោះ សាន សុឃី ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣"ភ" ចុះថ្ងៃទី ០៨-០២-៩៩ របស់តុលាការខេត្តកណ្ដាល ។

៦៩- ទណ្ឌិតឈ្មោះ យ៉ាន់ ស៊ឹម ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨"ក" ចុះថ្ងៃទី ១២-៩-៩៧ របស់តុលាការខេត្តកណ្ដាល ។

៧០- ទណ្ឌិតឈ្មោះ សៅ ពន្លឺង ហៅ ម៉េរ ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ២២"គ" ចុះថ្ងៃទី ១៥-៧-៩៨ របស់តុលាការខេត្តកណ្ដាល ។

៧១- ទណ្ឌិតឈ្មោះ មុត សុខ ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣"ភ" ចុះថ្ងៃទី ២៧-៧-៩៨ របស់តុលាការខេត្តកណ្ដាល ។

៧២- ទណ្ឌិតឈ្មោះ ហ៊ូរ ហ៊ិន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦"ក" ចុះថ្ងៃទី ០១-៥-៩៨ របស់តុលាការខេត្តកណ្ដាល ។

៧៣- ទណ្ឌិតឈ្មោះ យ៉ឹន សុគា ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧"ក" ចុះថ្ងៃទី ១៦-០២-៩៦ របស់តុលាការខេត្តកណ្ដាល ។

៧៤- ទណ្ឌិតឈ្មោះ សុខ ស្រ៊ុន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ៨ខែ តាមអំណាចសាលក្រមលេខ ០៥"គ" ចុះថ្ងៃទី ២៥-០២-៩៨ របស់តុលាការខេត្តកណ្ដាល ។

៧៥- ទណ្ឌិតឈ្មោះ ស៊ែម គា ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣"ក" ចុះថ្ងៃទី ១៤-០៨-៩៧ របស់តុលាការខេត្តកណ្ដាល ។

៧៦- ទណ្ឌិតឈ្មោះ យ៉ុន សំអាត ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ១៥"ភ" ចុះថ្ងៃទី ២៩-០៥-៩៩ របស់តុលាការខេត្តកណ្ដាល ។

៧៧- ទណ្ឌិតឈ្មោះ សួន ផល្លា ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលដីកាលេខ ៣៩ ចុះថ្ងៃទី ៥-០២-២០០០ របស់សាលាឧទ្ធរណ៍ ។

៧៨- ទណ្ឌិតឈ្មោះ ចេង ស៊ីន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ៦ខែ តាមអំណាចសាលក្រមលេខ ៣៥"រ" ចុះថ្ងៃទី ២៥-០៧-៩៦ របស់តុលាការខេត្តកណ្ដាល ។

៧៩- ទណ្ឌិតឈ្មោះ គង់ យឿន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៧០"ភ" ចុះថ្ងៃទី ០៧-០៨-៩៥ របស់តុលាការខេត្តកណ្ដាល ។

៨០- ទណ្ឌិតឈ្មោះ ឈឹម សាមី ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧"ភ" ចុះថ្ងៃទី ២៨-០៦-៩៩ របស់តុលាការខេត្តកណ្ដាល ។

៨១- ទណ្ឌិតឈ្មោះ ឡូញ ឃិន ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦"គ" ចុះថ្ងៃទី ២៣-០៥-៩៩ របស់តុលាការខេត្តកណ្ដាល ។

៩២- ទណ្ឌិតឈ្មោះ **ផល់ វណ្ណារី ហៅ ខែម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៥"ព" ចុះថ្ងៃទី ០៩-១២-៩៨ របស់តុលាការខេត្តកណ្តាល ។

៩៣- ទណ្ឌិតឈ្មោះ **ពៅ ញឹម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៥"ព" ចុះថ្ងៃទី ០៩-១២-៩៨ របស់តុលាការខេត្តកណ្តាល ។

៩៤- ទណ្ឌិតឈ្មោះ **ចាន់ វាសនា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៥"ព" ចុះថ្ងៃទី ០៩-១២-៩៨ របស់តុលាការខេត្តកណ្តាល ។

៩៥- ទណ្ឌិតឈ្មោះ **ឌុំ សោភ័ណ្ឌ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៥១"ភ" ចុះថ្ងៃទី ១៩-៩-៩៩ របស់តុលាការខេត្តកណ្តាល ។

៩៦- ទណ្ឌិតឈ្មោះ **ស្រ៊ុន ផាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥"ព" ចុះថ្ងៃទី ២៧-៥-៩៧ របស់តុលាការខេត្តកណ្តាល ។

មាត្រា ៤._ ត្រូវបើកលែងទោសឲ្យទណ្ឌិតចំនួន ៤នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១- ទណ្ឌិតឈ្មោះ **វណ្ណ មេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ២៦-០១-៩៥ របស់តុលាការខេត្តតាកែវ ។

២- ទណ្ឌិតឈ្មោះ **លាក់ តុក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ២៤-៥-៩៥ របស់តុលាការខេត្តតាកែវ ។

៣- ទណ្ឌិតឈ្មោះ **ម៉ាត់ ខាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦"ព" ចុះថ្ងៃទី ១១-៧-២០០០ របស់តុលាការខេត្តកណ្តាល ។

៤- ទណ្ឌិតឈ្មោះ **ពុក សៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ២៦-០១-៩៥ របស់តុលាការខេត្តតាកែវ ។

មាត្រា ៥._ ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៦._ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេចជាស្ថាពរ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# ព្រះរាជក្រឹត្យលេខ នស/រកត/១១០០/១៨៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក សូ ខុន

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# ព្រះរាជក្រឹត្យលេខ នស/រកត/១១០០/១៨៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក សូ សុវណ្ណ

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

# ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់សំណើនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ២០០០

## ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ ជស/ រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_____

ត្រាស់បង្គាប់

មាត្រា ១._ ត្រូវបានបំពាក់មេដាយ សេនា ជ័យសិទ្ធ ជូននាយទាហានជើងចាស់ចំនួន ១២ រូប ដូចមានរាយនាមខាងក្រោម : ។

១- ឯកឧត្តម ខេព មែន
២-ឯកឧត្តម ជៀន ដែល
៣- ឯកឧត្តម អៀ ជូនគីមម៉េង
៤-ឯកឧត្តម ប៊ុល ណាល់
៥-ឯកឧត្តម ប៊ូ ថន
៦-ឯកឧត្តម ស៊ើយ កែវ
៧- ឯកឧត្តម ប៉ាន់ ថៃ
៨- ឯកឧត្តម មាស គ្រួច
៩- ឯកឧត្តម ឌី គីន
១០- ឯកឧត្តម នួន សុខ
១១- ឯកឧត្តម ឈឹម ឌិមយ៉ុន
១១- ឯកឧត្តម ម៉ុល សុន្ធ

មាត្រា ២._ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា នេះតទៅ ។

ភ្នំពេញ, ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/១១០០/១៩០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ ជស/ រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

និ:ទិន្ន័យ:ទិ្វ:ដ
ក្រ......... ទំ......ពីទំព័រ



- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

ត្រាស់បង្គាប់

មាត្រា ១.- ត្រូវបានបំពាក់មេដាយ ព្រះរាជណាចក្រកម្ពុជា ថ្នាក់មហាសេនា ជូននាយទាហានជាន់ខ្ពស់ ចំនួន ០៥ រូប ដូចមាននាមខាងក្រោម :

១- នាយឧត្តមសេនីយ៍ផ្កាយមាស ៤ តែ គឹមយ៉ាន អត្តលេខ ០០០.០០៩ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

២- នាយឧត្តមសេនីយ៍ឯក ម៉ុល សារឿន អត្តលេខ ០០០.០១៧ អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ

៣- នាយឧត្តមសេនីយ៍ឯក មាស សុផា អត្តលេខ ០០០.០១៦ អគ្គមេបញ្ជាការរង និងជាមេបញ្ជាការ កងទ័ពជើងគោក

៤- នាយឧត្តមសេនីយ៍ឯក ខាន់ សាវឿន អត្តលេខ ០០០.០៤០ អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ

៥- នាយឧត្តមសេនីយ៍ឯក គន់ គីម អត្តលេខ ០០៤.២៩២ អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ

មាត្រា ២.- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា នេះតទៅ ។

ភ្នំពេញ, ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

## ព្រះរាជក្រឹត្យ នស/រកត/១១០០/១៩១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ អនុក្រឹត្យលេខ ៥៥ អនក្រ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់សំណើនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

ត្រាស់បង្គាប់

មាត្រា ១.- ត្រូវបានតែងតាំងឯកឧត្តម ញឹម វណ្ណដា ជា អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។

មាត្រា ២.- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា នេះតទៅ ។

ភ្នំពេញ, ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/១១០០/១៩២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- យោងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៩៦៩ រស ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០០

## ត្រាស់បង្គាប់

មាត្រា ១._ ត្រូវបានអនុញ្ញាតឲ្យឯកឧត្តម នូ សុវណ្ណារ៉ា លាឈប់ពីមុខតំណែងជាទីប្រឹក្សា សម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ។

មាត្រា ២._ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣._ ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ឲ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៤._ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា នេះតទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០០

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

***

## ព្រះរាជក្រឹត្យ នស/រកត/១១០០/១៩៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- យោងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៩៦៩ រស ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០០
- យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

មាត្រា ១._ តែងតាំងលោកជំទាវ ឡេង សុខឃាង ជាទីប្រឹក្សា សម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកសង្គមកិច្ច មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២._ ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ឲ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា នេះតទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

## II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

### អនុក្រឹត្យលេខ ៧៦ អនក្រ.បក

### ស្តីពី ការផ្ទេរផលធានថវិកា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/១១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមនស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១._ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤០០ លានរៀល (បួនរយលានរៀល) ពីជំពូក ៥១ (ចំណាយមិនបានគ្រោងទុក) នៃខវ៉ចំណាយមិនទាន់បែងចែកមកជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច និងវប្បធម៌) របស់ព្រឹទ្ធសភា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ។

មាត្រា ២._ ឥណទានថវិកាក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់ ជួយជនរងគ្រោះដោយទឹកជំនន់ ។

មាត្រា ៣._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្តេចប្រធានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា និងត្រាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៧៧ អនក្រ.បក

## ស្តីពី ការកែសំរួលអនុក្រឹត្យលេខ ៥៤ អនក្រ.បក

## ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ១៩៩៩

## ស្តីពីការកែសំរួលការរៀបចំ និង ការប្រព្រឹត្តិទៅរបស់

## គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ. ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីកែសំរួលការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

មាត្រា ១._ ត្រូវបានកែសំរួលមាត្រា ១ នៃអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការកែសំរួលការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១- សម្តេចនាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឥស្សរជនជាន់ខ្ពស់មួយរូប | អនុប្រធានទី១ |
| ៣- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៥ រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៩- តំណាងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១០- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |

ក្នុងករណីក្រសួងមានសហរដ្ឋមន្ត្រីដឹកនាំ សហរដ្ឋមន្ត្រីនោះត្រូវធ្វើជាអនុប្រធាន ឬសមាជិកនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

មាត្រា ២._ បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការ

អន្តរជាតិ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋលេខា-ធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានភារកិច្ចអនុវត្ត អនុក្រឹត្យនេះឲ្យបានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខា និងត្រានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៧៨ អនក្រ.បក

## ស្ដីពីការផ្ទេរឥណទានថវិកា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១._ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៥៤.៥៧៨.០០០ រៀល (សែសិបបួនលានប្រាំរយចិតសិបប្រាំបីពាន់រៀល) ពីជំពូក ១០ (បៀវត្ស និងប្រាក់បំណាច់) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) របស់ព្រឹទ្ធសភា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ។

មាត្រា ២._ ឥណទានថវិកា ក្នុងមាត្រា ១ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ទូទាត់ថ្លៃចលនៈវត្ថុ និងសំភារៈ ។

មាត្រា ៣._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្តេចប្រធានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា និងត្រានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ផ្សើចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

**អនុក្រឹត្យលេខ ៧៩ អនក្រ.បក**

**ស្តីពីការផ្ទេរឥណទានថវិកា**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១.-** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៥០០ លានរៀល (ប្រាំរយលានរៀល) ពីជំពូក៥០ (ចំណាយផ្សេងៗឥទានត្រៀមបំរុងសំរាប់តំលើងប្រាក់បៀវត្ស១០%) មកជំពូក១១ (ចំណាយបេដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) របស់ព្រឹទ្ធសភា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ។

**មាត្រា ២.-** ឥណទានថវិកា ក្នុងមាត្រា ១ខាងលើត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ សំរាប់សមាជិក សមាជិការព្រឹទ្ធសភា ចុះបេសកកម្មតាមមូលដ្ឋាន ភូមិ ឃុំ នានា ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្តេចប្រធានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា និងត្រានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

# អនុក្រឹត្យលេខ ៣៧១ អនក្រ.តត

## ស្តីពីការជូនមេដាយស្ហាបនាជាតិ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ឯកឧត្តមអភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា ១.** ត្រូវបានប្រគល់ មេដាយមាសស្ហាបនាជាតិ ជូនលោក SHIBUI OSAMU ប្រធានអង្គការ FFC ដែលបានបរិច្ចាគថវិកា ជួយកសាងអាគារសិក្សា និងចាក់ដី-គួសក្រហម ក្នុងទីធ្លាសាលាបឋមសិក្សា ហេង សំរិន ព្រែកហូរ ក្នុងស្រុកតាខ្មៅ ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់ ចំនួន ១៧.៥០០ ដុល្លារអាមេរិក ។

**មាត្រា ២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

**រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

***

# អនុក្រឹត្យលេខ ៣៧២ អនក្រ.តត
## ស្តីពីការជូនមេដាយសហមេត្រី

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**មាត្រា ១.-** ត្រូវបានប្រគល់ មេដាយសេនាសហមេត្រី ជូនមន្ត្រីអង្គការ កម្មវិធីស្បៀងអាហារពិភពលោក ០១រូប និងអង្គការហ្សេតេហ្សិត (GTZ) ០១រូប ដែលមានស្នាដៃល្អ ក្នុងការជួយអភិវឌ្ឍន៍ប្រទេសកម្ពុជា តាមរូបភាព សំរបសំរួល លើការងារស្បៀងពលកម្ម ហើយកសាងបានជាច្រើននូវហេដ្ឋារចនាសម្ព័ន្ធជនបទ ព្រមទាំងជួយបណ្តុះបណ្តាលមន្ត្រី ដែលពាក់ព័ន្ធនឹងគំរោង និងប្រជាជន នូវចំណេះដឹងអំពីគោលការណ៍សំខាន់ៗ សំរាប់អនុវត្តគំរោង ដូចមានរាយនាមខាងក្រោមនេះ ៖

១- លោក ភីធើហ្គេស (PETER GUEST)

២- លោកស្រី ម៉ាទីណា ប៊ឺធឆ្នែឌ័រ (MARTINA BERGSCHNEIDER)

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៣៧៣ អនក្រ.តត
## ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោកកម្ពុជា

### សំរេច

**មាត្រា ១.** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកវរសេនីយ៍ឯក ឆេ ខា មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ ដែលបានជួយកសាងទីបញ្ជាការកោះតាត្រក់ព្រែនរ៉ៃ ក្រុងព្រះសីហនុ ចំណាយអស់ទឹកប្រាក់ចំនួន ១២.០០០ ដុល្លារអាមេរិក ។

**មាត្រា ២.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៣៧៤ អនក្រ.តត
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ឯកឧត្តមអភិបាលខេត្តសៀមរាប

**សំរេច**

**មាត្រា ១.–** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ពាមល់ដាប់ថ្នាក់ ជូនសប្បុរសជនខ្មែរ ០៨ រូប ជនជាតិបរទេស ០១ រូប និងក្រុមហ៊ុនមួយ ដែលបានជួយឧត្តមធនធានផ្ទាល់ខ្លួន ក្នុងការកសាងអាគារថ្មីមួយខ្នង និងរបងប្រវែង ២២០ ម៉ែត្រ នៅស្នងការដ្ឋាននគរបាលខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម ៖

**ក– មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១- លោកឧកញ៉ា សុខ គង់ | | ទឹកប្រាក់ | ៥.១៧០ ដុល្លារអាមេរិក |
| ២- ក្រុមហ៊ុន BANGKOK AIRWAY | | ទឹកប្រាក់ | ៥.០៨០ ដុល្លារអាមេរិក |
| ៣- ឯកឧត្តម | សៀង ណាំ | ទឹកប្រាក់ | ៥.០៥០ ដុល្លារអាមេរិក |
| ៤- លោក | ឌួង សារុណ | ទឹកប្រាក់ | ៥.០៥០ ដុល្លារអាមេរិក |
| ៥- លោក | គោស៊ុំ សារឿន | ទឹកប្រាក់ | ៥.០០០ ដុល្លារអាមេរិក |

**ខ– មេដាយសំរិទ្ធស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- លោក | មេង សុទត្ថិ | ទឹកប្រាក់ | ៣.០០០ ដុល្លារអាមេរិក |
| ២- លោក | RICHARD C.HELFER (GRAND HOTEL D'ANGKOR) | ទឹកប្រាក់ | ១.៥០០ ដុល្លារអាមេរិក |
| ៣- លោក | ម៉ែន សារុំ | ទឹកប្រាក់ | ១.៤០០ ដុល្លារអាមេរិក |
| ៤- លោក | អ៊ុំ គួច | ទឹកប្រាក់ | ១.៣០០ ដុល្លារអាមេរិក |
| ៥- លោក | តាំង ប៊ុនចេង | ទឹកប្រាក់ | ១.២០០ ដុល្លារអាមេរិក |

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អភិបាលខេត្តខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

អនុក្រឹត្យលេខ ៣៧៥ អនក្រ.តត

ស្តីពីការ តែងតាំងមន្ត្រីរាជការ

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៥/អនក្រ/បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១._ ត្រូវបានតែងតាំងលោក ឆាន់ជួន ណារ៉ុន ជាអគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបន្ទុកផែនការនីយកម្មគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ននៅខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៣៧៦ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកោះកុង

**សំរេច**

មាត្រា ១.- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ០៧ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសំណង់ផ្សេងៗ ផ្នែកព្រះពុទ្ធសាសនានៅខេត្តកោះកុង ដូចមានរាយនាមខាងក្រោម ៖

**ក- មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សាយ តូចឋន** | បរិច្ចាគប្រាក់ | ៩.២២២.២២២ បាតថៃ |
| ២- ឯកឧត្តម | **រុន ផ្លាមកេសន** | បរិច្ចាគប្រាក់ | ៦១៥.៣៥០ បាតថៃ |

៣- ឧត្តមនាវាទោ ឡៅ ទិញ បរិច្ចាគប្រាក់ ១.២១៥.០០០ បាតថៃ
៤- លោកជំទាវ កាន់ ចន្ទ្រា បរិច្ចាគប្រាក់ ១.១០០.០០០ បាតថៃ

ខ- មេដាយប្រាក់ស្ថាបនាជាតិ

១- វរសេនីយ៍ទោ យន្ត មីន បរិច្ចាគទឹកប្រាក់ ៧.១៥០ ដុល្លារអាមេរិក

គ- មេដាយសំរិទ្ធស្ថាបនាជាតិ

១- ព្រះតេជគុណ ថាក លេកសាំងថង បរិច្ចាគទឹកប្រាក់ ១៦០.០០០ បាតថៃ
២- លោក ឡៃ អៀង បរិច្ចាគទឹកប្រាក់ ២០០.០០០ បាតថៃ

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា និង អភិបាលខេត្តខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

------

## អនុក្រឹត្យលេខ ៣៧៧ អនក្រ.គត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សំរេច

មាត្រា ១._ ត្រូវបានប្រគល់ មេដាយមាស ស្ថាបនាជាតិ ជូនលោក Y.C.PARK, Chairman of Tae Kwang Industrial Co.Ltd នៃសាធារណរដ្ឋកូរ៉េ ដែលបានធ្វើអំណោយជូនរាជរដ្ឋាភិបាលកម្ពុជា

សំរាប់ជួយសង្គ្រោះប្រជាពលរដ្ឋទទួលរងគ្រោះដោយទឹកជំនន់ នូវទឹកប្រាក់ចំនួន ១០០.០០០ ដុល្លារសហរដ្ឋអាមេរិក ។

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៣៧៨ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សំរេច

មាត្រា ១._ ត្រូវបានប្រគល់ មេដាយមាស ស្ថាបនាជាតិ ជូនលោក H.K.KIM ចៅហ្វាយខេត្ត KYUNGNAM នៃសាធារណៈរដ្ឋកូរ៉េ ដែលបានធ្វើអំណោយជូនរាជរដ្ឋាភិបាលកម្ពុជា សំរាប់ជួយសង្គ្រោះប្រជាពលរដ្ឋទទួលរងគ្រោះដោយទឹកជំនន់នូវទឹកប្រាក់ចំនួន ២០.០០០ ដុល្លារសហរដ្ឋអាមេរិក។

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

## III-ការងារបណ្ដាក្រសួង

## ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាស

ភ្នំពេញ, ថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០០

**ប្រកាសលេខ ១០៧៥ អយក.ប្រក**

**ស្ដីពីការបើក អនុវិទ្យាល័យ ហេង សារិន «អន្លង់ទ្រា» ជាឧបសម្ព័ន្ធ**

**អនុវិទ្យាល័យព្រែកអន្ទះ ស្ថិតក្នុងភូមិអន្លង់ទ្រា ឃុំព្រែកជ្រៃ ស្រុកកំពង់លាវ ខេត្តព្រៃវែង**

***

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៨៣ ស្ដីពីការបើកសាលារៀនមធ្យមសិក្សាកម្រិត១-កម្រិត២
- យោងលិខិតស្នើសុំរបស់ការិយាល័យអប់រំ ស្រុកកំពង់លាវលេខ ១៥៥-២០០០ សន.កណ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០០ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តព្រៃវែង ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

**សម្រេច**

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ **ហេង សារិន** «អន្លង់ទ្រា» ជាឧបសម្ព័ន្ធអនុវិទ្យាល័យព្រែកអន្ទះចាប់ពីឆ្នាំសិក្សា ២០០០-២០០១ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យត្រូវដឹកនាំដោយនាយករង ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយករងនៃអនុវិទ្យាល័យខាងលើមានសិទ្ធទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយដ្ឋានផែនការ និងប្រធាននាយដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង នាយកអនុវិទ្យាល័យព្រៃកអន្ទះ និង នាយករងអនុវិទ្យាល័យ ហេង ស៊ីន អន្លង់ទ្រា មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ។

ជ.រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

★★★

ភ្នំពេញ, ថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០០០

## ប្រកាសលេខ ១០៨០ អយក.ប្រក

### ស្តីពីការពង្រីក និង ប្តូរឈ្មោះអនុវិទ្យាល័យ «សំរោង» ទៅជាវិទ្យាល័យ «ឧត្តរមានជ័យ» ស្ថិតនៅក្នុង ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ

***

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៤ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៣ ស្តីពីការបើកថ្នាក់រៀនមធ្យមសិក្សាកម្រិត១-កម្រិត២
- យោងលិខិតស្នើសុំរបស់ មន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យលេខ ១៥០ អយកខ.មចទ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០០ ដោយមានយោបល់ឯកភាពពី អភិបាលខេត្តឧត្តរមានជ័យ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**សំរេច**

ប្រការ ១ : អនុញ្ញាតអោយពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ «សំរោង» បច្ចុប្បន្នទៅជាវិទ្យាល័យ «ឧត្តរមានជ័យ» ចាប់ពីឆ្នាំសិក្សា ២០០០-២០០១ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខ នៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយដ្ឋានផែនការ និងប្រធាននាយដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ និងវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

ជ.រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
រដ្ឋលេខាធិការ
អ៊ឹម សិទ្ធី

★★★